**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ...៦៩...សសរ

# សេចក្តីសម្រេច

## ស្តីពី

## ការបង្កើតគណៈកម្មការអន្តរក្រសួង ដើម្បីសិក្សាស្រាវជ្រាវករណីស្នើសុំសាងសង់ស្ពានបេតុងសំរាប់ថ្មើរជើងឆ្លងកាត់ផ្លូវវិថីធំៗ ដែលមានចរាចរកកស្ទះក្នុងរាជធានីភ្នំពេញរបស់ក្រុមហ៊ុន Cambodia quarry

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- យោងតាមសំណើរបស់សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សំរេច

**ប្រការ១** : បង្កើតគណៈកម្មការអន្តរក្រសួង ដើម្បីចុះពិនិត្យសិក្សាស្រាវជ្រាវអំពីការស្នើសុំសាងសង់ស្ពានបេតុងសំរាប់ថ្មើរជើងឆ្លងកាត់ផ្លូវវិថីធំៗ ដែលមានចរាចរកកស្ទះ ក្នុងរាជធានីភ្នំពេញរបស់ក្រុមហ៊ុន Cambodia quarry ដែលមានសមាសភាពដូចខាងក្រោម :-

| | |
|---|---|
| ១- តំណាងក្រសួងមហាផ្ទៃ | ប្រធាន |
| ២- តំណាងក្រសួងសាធារណការ និងដឹកជញ្ជូន | អនុប្រធាន |
| ៣- តំណាងក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | សមាជិក |
| ៤- តំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| ៥- តំណាងអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា | សមាជិក |
| ៦- តំណាងក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ | សមាជិក |

៧- តំណាងទីស្តីការគណៈរដ្ឋមន្ត្រី សមាជិក

៨- តំណាងក្រសួងបរិស្ថាន សមាជិក

៩- តំណាងសាលាក្រុងភ្នំពេញ សមាជិក

**ប្រការ២** : គណៈកម្មការអន្តរក្រសួងនេះមានភារកិច្ចដូចតទៅ :

- ចុះពិនិត្យសិក្សាស្រាវជ្រាវស៊ីជំរៅដល់ទីកន្លែង ដែលស្នើសុំសាងសង់ស្ពានបេតុងសំរាប់ ធ្វើរជើងឆ្លងកាត់ដងវិថីធំៗទាំង ០៣ កន្លែងនោះ
- ពិនិត្យលើគំរោងសាងសង់របស់សាម៉ីក្រុមហ៊ុន
- វាយតម្លៃអំពីហេតុផលប៉ះពាល់ដល់បរិស្ថាន និងលំនៅស្ថានប្រជាជន
- ធ្វើរបាយការណ៍សរុបលទ្ធផលការងារ និងលើកវិធានការ ព្រមទាំងសំណូមពរជូនប្រមុខរាជរដ្ឋាភិបាលពិនិត្យ និងសំរេច ។

**ប្រការ៣** : សមាជិកគណៈកម្មការត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធានគណៈកម្មការ ។

**ប្រការ៤** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ រដ្ឋមន្ត្រីក្រសួងបរិស្ថាន អគ្គលេខាធិការក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា អភិបាលក្រុងភ្នំពេញ និងគណៈកម្មការ ដូចមានចែងក្នុងប្រការ ១ ខាងលើត្រូវទទួលបន្ទុកអនុវត្តសេចក្តីសំរេចនេះ ឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១១ ខែ កក្កដា ឆ្នាំ ២០០៥

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- ដូចប្រការ ៤
- ឯកសារ- កាលប្បវត្តិ

Chanthi\Samrech.doc